# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាអគ្គសញ្ញាលាបថ្វាសនៅភ្នំពេញថ្មី
# ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៨
## *យើងជាមេត្រូវមានគំនិតច្បាស់លាស់*

អត្ថបទទី១៖ កក ១,១៥-១៧.២០ក.២០គ-២៦
អត្ថបទទី២៖ ១យហ ៤,១១-១៦
ដំណឹងល្អ៖ យហ ១៧,១១ខ-១៩

បងប្អូនជាទីស្រឡាញ់!

ធ្លាប់ឮគេថាសាសនាយេស៊ូ ណែនាំឲ្យស្អប់ឪពុកម្តាយ មិនគោរពឪពុកម្តាយ ប៉ុន្តែគ្មានឯកសារមួយនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ សម្ព័ន្ធមេត្រីថ្មី ឬសេចក្តីប្រកាសមួយដែលចេញពីសម្តេចប៉ាបដែលថា យើងជាគ្រីស្តបរិស័ទអត់គោរពឪពុកម្តាយនោះទេ។ ហេតុអីគេនិយាយដូចនេះ? គេនិយាយតៗគ្នាតាំងពីដើមមក ណែនាំឲ្យគេមើលងាយសាសនាយើង។ គេថាអ្នកដែលចូលយេស៊ូជាកូនអកតញ្ញូ តើពេលណាដែលលោកឪពុកបាននិយាយថា "កុំរវីរវល់ជាមួយឪពុកម្តាយ?" ប៉ុន្តែយើងមានសម្ព័ន្ធត្រីចាស់ ធម្មវិន័យ១០ប្រការ ត្រង់ប្រការទី៣ថា "**សូមគោរពមាតាបិតា**"។ ព្រះយេស៊ូមានព្រះបន្ទូលថា "**បងប្អូននិងឪពុកម្តាយរបស់ខ្ញុំជាអ្នកធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់**"។ នៅក្នុងឯកសារព្រះសហគមន៍ នៅក្នុង២០០០ឆ្នាំកន្លងមក ដែលមានការអប់រំពីសម្តេចប៉ាបតៗ នៅពេលណាយើងបាននិយាយថា យើងជាគ្រីស្តបរិស័ទ យើងអត់គោរពឪពុកម្តាយ? យើងជាគ្រីស្តបរិស័ទ យើងអត់ធ្វើបុណ្យសពឲ្យឪពុកម្តាយ? នេះគេហៅថាព័ត៌មានមិនពិត (Fuck News)។ ថ្ងៃនេះយើងគោរពទិវានៃការផ្សព្វផ្សាយព័ត៌មានកាតូលិក សម្តេចប៉ាបឲ្យយើងគិតអំពីព័ត៌មានមិនពិត។ ថ្ងៃនេះខ្ញុំ លើកឧទាហរណ៍មួយដែលគេនិយាយតៗ និងណែនាំឲ្យសាសនារបស់យើងមានឈ្មោះអត់សូវល្អនៅក្នុងប្រទេសកម្ពុជា ដោយសារគេថាយើងណែនាំឲ្យកូនចៅគេអត់មានចិត្តកតញ្ញូចំពោះឪពុកម្តាយ។

បន្តិចទៀតបងប្អូននឹងទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ដែលណែនាំឲ្យយើងស្គាល់សេចក្តីពិត។ យើងជាគ្រីស្តបរិស័ទ យើងរស់នៅជាមួយព្រះយេស៊ូដែលជាសេចក្តីពិតផ្ទាល់។ ព្រះយេស៊ូដែលណែនាំឲ្យយើងរស់នៅក្នុងសេចក្តីពិត និងព្រះវិញ្ញាណដ៏វិសុទ្ធដែលយើងនឹងទទួល ជាសេចក្តីពិតដ៏ពិតប្រាកដ ដើម្បីបំភ្លឺជីវិតរបស់យើង ដើម្បីឲ្យយើងរស់នៅក្នុងពិភពលោកនេះ ធ្វើជាគ្រីស្តបរស័ទ ដោយចេះបង្ហាញអំពីជីវិតដ៏ពិសេសដែលយើងបានទទួលពីព្រះជាម្ចាស់។

សព្វថ្ងៃមុន យើងចូលចិត្តចែករំលែកព័ត៌មានតាមមធ្យោបាយថ្មីៗដែលយើងមាន កាលពីខ្ញុំមកប្រទេសកម្ពុជាឆ្នាំ១៩៩៨ គឺ២០ឆ្នាំមុន នៅពេលនោះខ្ញុំអត់ទាន់មានអ្វីពិសេសដើម្បីទំនាក់ទំនងជាមួយឪពុកម្តាយ ជាមួយបងប្អូននៅប្រទេសបារាំង។ នៅពេលលោកអភិបាលអេមីល ឲ្យ

ខ្ញុំទៅស្វាយស៊ីសុផុន ក៏ទូរសព្ទដៃនៅខ្មែរមិនទាន់មានប៉ុន្មានទេ ទូរសព្ទដៃរបស់ខ្ញុំដំបូងបង្អស់មានទំងន់ជិតមួយគីឡូធ្ងន់ណាស់។ នៅស្វាយស៊ីសុផុនសម័យ២០ឆ្នាំមុន គេប្រើវិទ្យុទាក់ទង (អាយកូម) និងពេលខ្ញុំចង់និយាយទូរសព្ទជាមួយឪពុកម្ដាយ ខ្ញុំត្រូវការទៅហាងដែលមានអ៊ីនធឺណែត រង់ចាំមួយម៉ោងដើម្បីផ្ញើអ៊ីមែលមួយ ដោយសារអ៊ីនធឺណែតអត់មាន 2G 3G 4G អត់មានអីសោះ។

ប៉ុន្តែសព្វថ្ងៃ ប្អូនៗរស់នៅក្នុងពិភពដែលផ្សព្វផ្សាយលឿន និងព័ត៌មានពីមួយថ្ងៃទៅមួយថ្ងៃ យើងអាចចែករំលែកអ្វីៗទាំងអស់ដែលយើងមាននៅក្នុងចិត្តយើង។ ជួនកាលណែនាំឲ្យយើងយល់ច្រឡំគ្នា និងវង្វេងគ្នា ដោយសារសព្វថ្ងៃ យើងចង់ចែករំលែកអ្វីៗទាំងអស់ មានព័ត៌មានមួយចំនួនមិនពិត មានព័ត៌មានមួយចំនួនដែលណែនាំឲ្យយើងសោកសៅ និងព័ត៌មានមួយចំនួនណែនាំឲ្យយើងមើលងាយគេ និយាយដើមគេដែលអត់មានគោរពសោះ។ ថ្ងៃនេះយើងទទួលព្រះវិញ្ញាណដ៏វិសុទ្ធនៃសេចក្ដីពិត ណែនាំឲ្យយើងភ្ញាក់ស្មារតី ដោយសារព្រះយេស៊ូណែនាំឲ្យយើងទៅជាគ្រីស្តបរិស័ទ ដែលរស់នៅតាមផ្លូវដែលព្រះយេស៊ូបានរៀបចំ ដើម្បីប្រកាសដំណឹងល្អនៅក្នុងជីវិតរបស់យើង ពិភពរបស់យើង ឲ្យយើងចេះប្រើឧបករណ៍ផ្សព្វផ្សាយព័ត៌មាន ទាំងហ្វេសប៊ុក ទាំងធ្វីសធ័រ ទាំងម៉េសសិនជឺ ទាំងប្រព័ន្ធផ្សេងទៀត ដើម្បីបង្ហាញពីសេចក្ដីពិតនៃជីវិតយើង សេចក្ដីពិតនៃសេចក្ដីស្រឡាញ់ ដើម្បីឲ្យយើងទៅជាសាក្សីនៃសេចក្ដីសុខសាន្ត នៅក្នុងពិភពលោករបស់យើង។

ថ្ងៃនេះយើងមានយុវជនមួយចំនួនដែលទទួលអគ្គសញ្ញាលាបថ្ងាស យើងមានមេក្រុមកាយឫទ្ធិដែលជិត១៥០នាក់។ ថ្ងៃនេះ ខ្ញុំចង់និយាយឲ្យយើងច្បាស់ **៤ចំណុច** សម្រាប់បងប្អូនទាំងអស់ដែលអង្គុយនៅវិហារនេះ ប៉ុន្តែជាពិសេសសម្រាប់ប្អូនដែលទទួលអគ្គសញ្ញាលាបថ្ងាស (ព្រះវិញ្ញាណដ៏វិសុទ្ធនៃសេចក្ដីពិត) សម្រាប់មេក្រុមកាយឫទ្ធិដែលជាមេដឹកនាំកូន។ ដូច្នេះ យើងទទួលខុសត្រូវយ៉ាងខ្ពស់ មិនមែនទទួលខុសត្រូវល្មមៗទេ មិនមែនទទួលខុសត្រូវស្ទើរ និងខ្សោយ។ បន្ថែមទៀតយើងមានកូនក្មេងបីរយនាក់ដែលមក នៅពេលយើងមានកូនក្មេងរាប់រយនាក់ដែលជួបជុំគ្នារាល់អាទិត្យនៅតាមកន្លែងយើង យើងជាមេដែលត្រូវការមានគំនិតច្បាស់លាស់។ សម្រាប់យើងដែលជាយុវជនគ្រីស្តបរិស័ទ សម្រាប់យើងដែលជាមេក្រុមកាយឫទ្ធិ៖

**ចំណុចទីមួយ** យើងជាមេក្រុមកាយឫទ្ធិកាតូលិក យើងជាយុវជនកាតូលិក យើងទាំងអស់គ្នាជាគ្រីស្តបរិស័ទកាតូលិក។ កាតូលិកដែលមានមួយចំនួនតូចណាស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រឹមតែ២ម៉ឺននាក់នៅក្នុងចំណោម១៦លាននាក់។ ចំណុចទីមួយ របស់យើងដែលយើងត្រូវការច្បាស់លាស់ គឺ **យើងផ្ដល់សាក្សីភាពអំពីអំពីអ្វីខ្លះ? ដំណឹងល្អដែលយើងប្រកាសគឺត្រូវដឹង**

**ច្បាស់ថាយើងប្រកាសអំពីអ្វី? យើងផ្តល់សាក្ខីភាពអំពីអ្វី?** យើងត្រូវការយល់ពីដំណឹងល្អ ដែលយើងប្រកាស គឺទីមួយ ចំណាងជើងយ៉ាងធំ "**ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់!**"។ ទីពីរ ធម្មវិន័យរបស់យើងមានតែមួយគត់ យើងត្រូវឆ្លាក់នៅក្នុងដួងចិត្តរបស់យើង គឺ "**ត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ**"។ ទីបី **យើងមានមិត្តសម្លាញ់មួយយ៉ាងពិសេសគឺព្រះយេស៊ូ**។ សេចក្តីប្រកាសរបស់យើង ដំណឹងល្អរបស់មានតែ ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ ស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះយេស៊ូ ដូច្នេះយើងបមានគំរូមួយយ៉ាពិសេស និងព្រះយេស៊ូបានទទួលយើងជាមិត្តសម្លាញ់មួយយ៉ាងពិសេស។ ដូច្នេះ ឲ្យយើងចូលយ៉ាងជ្រៅនៅក្នុងការប្រកាសដំណឹងល្អរបស់យើង កុំឲ្យយើងកែច្នៃសេចក្តីពិត កុំឲ្យយើងទៅជាអ្នកប្រកាសដំណឹងល្អផ្សេងពីអ្វីដែលព្រះយេស៊ូបានណែនាំយើង។

**ចំណុចទីពីរ** យើងបាននៅក្នុងអំណោយទានដែលយើងទទួល គឺព្រះវិញ្ញាណដែលផ្តល់ឲ្យមានប្រាជ្ញាឈ្លាសវៃ និងព្រះវិញ្ញាណនាំឲ្យយើងចេះពិចារណា ដឹងខុសដឹងត្រូវ។ យើងទៅជាគ្រីស្តបរិស័ទ ឲ្យយើងនៅក្នុងជីវិតប្រចាំថ្ងៃ ឲ្យយើងចេះពិចារណាអ្វីដែលល្អ អ្វីដែលមិនល្អ អ្វីដែលត្រឹមត្រូវ អ្វីដែលខុស។ សម្រាប់យុវជន សម្រាប់អ្នកទទួលខុសត្រូវ សម្រាប់ក្រុមកាយឫទ្ធិ នៅពេលយើងណែនាំកូនក្មេងយើងត្រូវការដឹង នេះល្អ នេះមិនល្អ។ ដើម្បីដឹងថាល្អមិនល្អយើងត្រូវឲ្យយើងមើលព្រះយេស៊ូ ស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះយេស៊ូបានស្រឡាញ់យើង។ ដូច្នេះពេលយើងណែនាំកូនក្មេង គឺឲ្យកូនក្មេងចេះស្រឡាញ់ ណែនាំឲ្យកូនក្មេងចេះស្រឡាញ់ឪពុកម្តាយ ណែនាំឲ្យកូនក្មេងចេះស្រឡាញ់ធម្មជាតិ សង្គម និងជីវិតផ្ទាល់ខ្លួនដែលមានតម្លៃ។ ឲ្យយើងចេះមើលអ្វីដែលល្អនិងមិនល្អ ឲ្យយើងចេះទទួលខុសនិងត្រូវ ដើម្បីទៅមុខនៅក្នុងជីវិតរបស់យើង។ ពន្លឺរបស់យើងដើម្បីមើលឃើញ គឺពន្លឺនៃសេចក្តីស្រឡាញ់របស់ព្រះយេស៊ូជានិច្ច។ ដោយសារពេលយើងរស់នៅក្នុងភាពងងឹត យើងមើលមិនឃើញនូវអ្វីដែលល្អឬមិនល្អ។ ប៉ុន្តែប្រសិនបើយើងបើកភ្លើង ឃើញពន្លឺដែលមកពីព្រះវិញ្ញាណដ៏វិសុទ្ធ ពន្លឺដែលណែនាំឲ្យមានសេចក្តីស្រឡាញ់របស់ព្រះអង្គដែលបំភ្លឺយើង នាំឲ្យយើងមើលឃើញអ្វីដែលល្អមិនល្អ។ យើងត្រូវការសម្រេចចិត្ត ដោយទទួលពន្លឺនៃសេចក្តីស្រឡាញ់ដែលមកពីព្រះជាម្ចាស់ ដើម្បីឲ្យគ្រប់សកម្មភាពរបស់យើង អាចណែនាំឲ្យបងប្អូនឯទៀតៗរកឃើញសេចក្តីសុខសាន្ត រកឃើញសុភមង្គល។ ប្រសិនបើ ខ្ញុំណែនាំឲ្យឪពុកម្តាយពិបាកចិត្ត មានន័យថាអ្វីដែលបានធ្វើមិនត្រឹមត្រូវ។ ប្រសិនបើ ខ្ញុំណែនាំឲ្យបងប្អូនខ្ញុំយំ និងឈឺចាប់ មានន័យថាអ្វីដែលខ្ញុំបានសម្រេចចិត្តមិនត្រូវទេ។ ប្រសិនបើ ខ្ញុំណែនាំឲ្យក្នុងសាលាខ្ញុំគេបាក់បែកគ្នា នៅក្នុងព្រះសហាគមន៍គេនិយាយគ្នាទៅវិញទៅមកដោយមើលងាយគ្នា មានន័យថាអ្វីៗដែលខ្ញុំកំពុងធ្វើវាខុសនឹងសេចក្តីស្រឡាញ់របស់

ព្រះជាម្ចាស់។ អ្វីដែលខ្ញុំធ្វើ ខ្ញុំទទួលខុសនិងត្រូវ ដើម្បីណែនាំឲ្យធ្វើអំពើល្អ និងណែនាំឲ្យមនុស្សដែលនៅជុំវិញខ្ញុំមានសេចក្ដីសុខ មានកម្លាំងកាយកម្លាំងចិត្ត និងមានសេចក្ដីសង្ឃឹមជានិច្ច។ នេះចំណុចទីពីរ។

**ចំណុចទីបី** ព្រះអំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធដែលយើងទទួល **"ព្រះវិញ្ញាណនាំឲ្យមានសេចក្ដីអង់អាច"** ឲ្យមានសេចក្ដីក្លាហាន ដើម្បីស្គាល់និងចេះគោរពកោតខ្លាចព្រះបិតា និងណែនាំជីវិតរបស់យើងឲ្យរស់នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ ឲ្យចេះគោរពព្រះជាម្ចាស់ ដើម្បីរស់នៅក្នុងទំនាក់ទំនងដែលយើងមានយ៉ាងពិសេស ជាមួយព្រះយេស៊ូដែលជាមិត្តរបស់យើង។ ប្រសិនបើយើងមិនស្ដាប់ មិនជិតស្និទ្ធជាមួយព្រះយេស៊ូទេ តើត្រូវធ្វើយ៉ាងម៉េចដើម្បីរស់នៅជាគ្រីស្តបរិស័ទ? ជារៀងរាល់ថ្ងៃដើម្បីស្ដាប់ដំណឹងល្អ គឺព្រះបន្ទូលដែលព្រះយេស៊ូកំពុងនិយាយសម្រាប់ខ្ញុំ។ ជាព្រះយេស៊ូដែលមានរឿងមួយចង់និយាយដល់ខ្ញុំ។ ថ្ងៃនេះ ព្រះយេស៊ូចង់ឲ្យខ្ញុំទៅប្រកាសដំណឹងល្អ ព្រះយេស៊ូចង់ឲ្យខ្ញុំណែនាំអ្នកជំងឺជាសះស្បើយ។ ព្រះយេស៊ូចង់ឲ្យខ្ញុំធ្វើយ៉ាងម៉េចដើម្បីណែនាំមនុស្សតូចតាចឲ្យមានសេចក្ដីសង្ឃឹម ធ្វើយ៉ាងម៉េចដើម្បីឲ្យមនុស្សដែលគេមើលងាយនៅក្នុងសង្គមអាចមានតម្លៃថ្លៃថ្នូរដូចគេដូចឯង។ សម្រាប់យើងជាយុវជន និងជាពិសេសសម្រាប់មេក្រុមកាយឫទ្ធិ យើងត្រូវតែធ្វើយ៉ាងម៉េចទោះបីគេមិនមែនកូនក្មេងគ្រីស្តបរិស័ទនៅកន្លែងច្រើនមែន ប៉ុន្តែធ្វើយ៉ាងម៉េចឲ្យគេយល់ថាជីវិតគេក៏មានតម្លៃ ដោយសារព្រះជាម្ចាស់បានបង្កើតយើង និងដោយសារយើងមានមិត្តមួយយ៉ាងពិសេស មិត្តភាពរវាងយើងនិងព្រះយេស៊ូជាមិត្តភាពដែលយើងត្រូវតែទទួល ដើម្បីរស់នៅក្នុងពន្លឺនៃព្រះជាម្ចាស់។

**ចំណុចទីបួន ឲ្យយើងទៅជាសាក្សីនៃសេចក្ដីក្លាហាននៃសេចក្ដីពិត** សេចក្ដីពិត អត់មានអីច្រើនទេ គឺធ្វើយ៉ាងម៉េចដើម្បីរស់នៅតាមព្រះយេស៊ូ។ មានន័យថារស់នៅជាមួយព្រះយេស៊ូនៅក្នុងសេចក្ដីស្រឡាញ់។ ប៉ុន្តែប្រយត្ន ដោយសារពេលយើងរស់នៅជាមួយព្រះយេស៊ូ មានមនុស្សមួយចំនួនគេអត់ពេញចិត្តជាមួយយើង។ នៅពេលគេចាប់ព្រះយេស៊ូ ដើម្បីទៅសម្លាប់ព្រះយេស៊ូ ព្រះយេស៊ូបានធ្វើអីខុសបានជាជាប់ឈើឆ្កាងដូចនេះ? មានតែមួយម៉ាត់ដែលគេថាខុសគឺព្រះយេស៊ូថា "**ជាព្រះបុត្រារបស់ព្រះជាម្ចាស់**"។ ប៉ុន្តែព្រះយេស៊ូបានធ្វើអំពើល្អ ឲ្យអ្នកជំងឺបានជាសះស្បើយ អ្នកក្រីក្រមានសេចក្ដីសុខ ឲ្យគេមានជីវិតដ៏បរិសុទ្ធណ៍។ ជួនកាលគាត់ធ្វើខុសនឹងធម្មវិន័យ ដោយសារថ្ងៃសប្ប័ទហាមធ្វើការជាដាច់ខាត និងព្រះយេស៊ូព្យាបាលគេ ប៉ុន្តែព្រះយេស៊ូសួរតើយើងចង់ឲ្យគេស្លាប់ឬចង់ឲ្យគេរស់។ ដូច្នេះគេស្អប់ព្រះយេស៊ូ និងព្រះយេស៊ូក៏មានព្រះបន្ទូលដែរ "**ដូចគេបានស្អប់ខ្ញុំ ប្រហែលគេក៏ស្អប់អ្នករាល់គ្នាដែរ**"។ ដោយសារនៅកន្លែងណាដែលមានពុករលួយ ប្រសិនបើយើងធ្វើតាមគេស្រួលណាស់ ប៉ុន្តែប្រសិនបើយើងប្រឆាំងខ្ញុំមិនឲ្យលុយ ខ្ញុំ

មិនបង់ ខ្ញុំទៅមុខដោយមានចិត្តស្មោះត្រង់ និងសមត្ថភាពរបស់ខ្ញុំ នោះគេស្អប់យើងដោយមិនចូលនៅក្នុងរបៀបគេ។ នៅពេលគេ ណែនាំឲ្យនិយាយកុហកលោកគ្រូអ្នកគ្រូនិងឪពុកម្ដាយ ប្រសិនបើយើងមិនព្រមធ្វើគេស្អប់យើង។ តាមពិតធ្វើជាគ្រីស្តបរិស័ទ យើងរស់នៅជាមួយព្រះយេស៊ូដែលជួបទុក្ខលំបាក ដោយសារមនុស្សមួយចំនួនគេមិនយល់ តែចុងបញ្ចប់ទើបយល់ថាព្រះជាម្ចាស់យល់ចិត្តយើងយ៉ាងច្បាស់ ដើម្បីណែនាំឲ្យយើងមានជីវិតថែមទៀត។

ដូច្នេះយើងចាំ៤ចំណុចៈ **ទីមួយ** យើងស្គាល់យល់យ៉ាងច្បាស់អំពីដំណឹងល្អដែលយើងត្រូវតែប្រកាស ព្រះជាម្ចាស់នៃសេចក្ដីស្រឡាញ់ ស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះយេស៊ូ និងធ្វើជាមិត្តជិតស្និទ្ធជាមួយព្រះយេស៊ូ។ **ទីពីរ** ឲ្យយើងចេះពិចារណា អ្វីដែលល្អ អ្វីដែលមិនល្អ ដើម្បីទទួលខុសត្រូវនៅក្នុងសង្គម ដើម្បីណែនាំឲ្យអ្នកដទៃមានសេចក្ដីសុខ។ **ទីបី** ឲ្យយើងចេះកោតខ្លាចព្រះជាម្ចាស់ ដោយស្រឡាញ់ព្រះជាម្ចាស់ ជិតស្និទ្ធជាមួយព្រះជាម្ចាស់នៅក្នុងការអធិដ្ឋានដោយរក្សាព្រះបន្ទូលព្រះអង្គជានិច្ច។ **ទីបួន** ឲ្យយើងទៅជាសាក្សី ពោរពេញដោយសេចក្ដីក្លាហាន ដើម្បីបង្ហាញសេចក្ដីពិត ដើម្បីរស់នៅក្នុងជីវិតសាមញ្ញធម្មតាជាមួយបងប្អូនឯទៀតៗតាមរបៀបព្រះយេស៊ូដែរ។

ដូច្នេះយើងចូលទៅក្នុងការអធិដ្ឋានថែមទៀត ដើម្បីឲ្យបងប្អូនទាំងអស់មានសេចក្ដីសុខ ឲ្យយើងរស់នៅក្នុងជីវិតដ៏ពិសេស និងជាមួយសម្ដេចប៉ាប យើងអធិដ្ឋានដល់ព្រះយេស៊ូដែលណែនាំឲ្យយើងទៅជាសេចក្ដីពិតៈ

បពិត្រព្រះអម្ចាស់ សូមណែនាំយើងខ្ញុំឲ្យទៅជាឧបករណ៍នៃសេចក្ដីសុខសាន្ត។

សូមឲ្យខ្ញុំទទួលស្គាល់ អំពើអាក្រក់ដែលចូលនៅក្នុងពីភពលោករបស់យើង និងដែលណែនាំឲ្យយើងបាក់បែកគ្នា។

សូមណែនាំឲ្យយើងដកចេញថ្នាំពុល នៅក្នុងការវិនិច្ឆ័យរបស់ខ្ញុំ។

សូមជួយខ្ញុំ ដើម្បីឲ្យខ្ញុំចេះនិយាយជាមួយបងប្អូនឯទៀតៗ មិនមែនទុកគេជាសាសន៍ដទៃ ប៉ុន្តែគោរពគេ ស្រឡាញ់គេដូចជាបងប្អូនបង្កើត។

បពិត្រព្រះម្ចាស់! ព្រះអង្គមានព្រះហឫទ័យប្រោសប្រណីជានិច្ច ខ្ញុំអាចទុកចិត្តលើព្រះអង្គយ៉ាងពិតប្រាកដ។

សូមព្រះអង្គណែនាំខ្ញុំ ដើម្បីឲ្យពាក្យសម្ដីរបស់ខ្ញុំទាំងអស់ទៅជាពូជនៃអំពើល្អសម្រាប់ពិភពលោក។

នៅកន្លែងណាដែលគេនិយាយដើមគេ សុមឲ្យខ្ញុំធ្វើយ៉ាងម៉េចដើម្បីឲ្យខ្ញុំស្តាប់សេចក្តីពិត និងចេះស្តាប់គ្នាទៅវិញទៅមក។

នៅកន្លែងណាដែលមានភាពរញ៉េរញ៉ៃ ខ្ញុំធ្វើយ៉ាងម៉េចដើម្បីចេះបង្កើតភាពសុខដុមរមនា។

នៅកន្លែងណាដែលមានភាពមិនច្បាស់លាស់ ខ្ញុំធ្វើយ៉ាងម៉េច ដើម្បីណែនាំឲ្យមានពន្លឺស្រស់ថ្លា។

នៅកន្លែងណាដែលមានការបណ្តេញបងប្អូនឯទៀតៗ ឲ្យខ្ញុំធ្វើយ៉ាងម៉េចដើម្បីចែករំលែកសេចក្តីសុខពីព្រះយេស៊ូ។

នៅកន្លែងណាដែលគេផ្សព្វផ្សាយដ៏អស្ចារ្យ ឲ្យខ្ញុំគិតនូវអ្វីដែលជាសេចក្តីពិត និងធ្វើយ៉ាងម៉េចដើម្បីកាត់បន្ថយការអស្ចារ្យនៅក្នុងរបៀបស្លូតបូត និងសុភាពរាបសារ។

នៅកន្លែងណាដែលយើងសួរសំណួរឥតប្រយោជន៍ ឲ្យយើងធ្វើយ៉ាងម៉េចដើម្បីរស់នៅក្នុងជម្រៅនៃដួងចិត្តរបស់ខ្ញុំដែលណែនាំឲ្យមនុស្សមានសំណួរដ៏សំខាន់បំផុតដើម្បីដឹកនាំជីវិតយើង។

នៅកន្លែងណាដែលយើងផាត់ពណ៌ ឲ្យខ្ញុំធ្វើយ៉ាងម៉េច ដើម្បីបង្កើតការទុកចិត្តគ្នា។

នៅកន្លែងណាដែលមានការខ្ពើមគ្នា ស្អប់គ្នា ឲ្យយើងធ្វើយ៉ាងម៉េចដើម្បីដឹកនាំការគោរពគ្នាទៅវិញទៅមក។

នៅកន្លែងណាដែលមានការកុហក កែច្នៃសេចក្តីពិត យើងធ្វើយ៉ាងម៉េចដើម្បីណែនាំសេចក្តីពិតយ៉ាងពិតប្រាកដ។ អាម៉ែន៕